ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ខ្សាច់លាវ
## រយៈពេល ៣ ឆ្នាំ ( ២០១៨ - ២០២០ )

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | ខ្សាច់លាវ |
| ភូមិ | ៖ | ខ្សាច់លាវ |
| ឃុំ | ៖ | អូរគ្រៀង |
| ស្រុក | ៖ | សំបូរ |
| ខេត្ត | ៖ | ក្រចេះ |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ខ្សាច់លាវ

## រយៈពេល ៣ ឆ្នាំ (២០១៨ - ២០២០)

| | | |
|---|---|---|
| សហគមន៍នេសាទ | ៖ | ខ្សាច់លាវ |
| ភូមិ | ៖ | ខ្សាច់លាវ |
| ឃុំ | ៖ | អូរគ្រៀង |
| ស្រុក | ៖ | សំបូរ |
| ខេត្ត | ៖ | ក្រចេះ |

# មាតិកា
## ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍


**១-ស្ថានភាពទូទៅ**..........៣
**២-អំពីប្រជាសាស្ត្រនិងសេដ្ឋកិច្ចសង្គម**..........៤
ក- ប្រជាសាស្ត្រ..........៤
ខ-មុខរបរ..........៤
**៣-កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងសហគមន៍**..........៥
ក-ទីតាំង..........៥
ខ-ដែននេសាទ..........៥
គ-តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស..........៥
ឃ-ធនធានជលផល..........៥
**៤-ការធ្វើនេសាទ**..........៦
ក-អ្នកនេសាទ..........៦
ខ-ឧបករណ៍នេសាទ..........៦
គ-ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ..........៧
**៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ**..........៧
ក-ទស្សនវិស័យ..........៧
ខ-គោលបំណង..........៧
គ-ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍..........៨
គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ..........៨
គ២-ផែនការការពារកន្លែងអភិរក្សសហគមន៍..........៩
គ៣-ផែនការពង្រឹងការគ្រប់គ្រងសហគមន៍នេសាទ..........១០
គ៤-ផែនការប្រជុំគណៈកម្មការ និងក្រុមល្បាត..........១១
គ៥-ផែនការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ..........១២
គ៦-ផែនការផ្សព្វផ្សាយ..........១៣
គ៧-ផែនការបណ្តុះបណ្តាល..........១៤
គ៨-ផែនការចំណូលថវិកាទ្រទ្រង់សហគមន៍..........១៥
គ៩-ផែនកែលម្អដែននេសាទ..........១៥
គ១០-ផែនការអភិវឌ្ឍវារីវប្បកម្ម..........១៦
គ១១-ផែនការមុខរបរចិញ្ចឹមជីវិត..........១៦
ឃ.ផែនការយុទ្ធសាស្ត្រ..........១៧
-តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍រយៈពេល៣ឆ្នាំ..........១៨
-តារាងកម្មវិធីការងារ..........២២

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១-ស្ថានភាពទូទៅ

សហគមន៍នេសាទ**ខ្សាច់លាវ** បានបង្កើតឡើងនៅថ្ងៃទី១៤ ខែវិច្ឆិកាឆ្នាំ ២០១០ ចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍នៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១១ និងបានចុះបញ្ជីទទួលស្គាល់ជា ផ្លូវការដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ គាំទ្រដោយអង្គការ CAA/Oxfam Australia ។ ដោយផុតអាណត្តិ សហគមន៍នេសាទបានបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទជាថ្មីឡើងវិញនៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៤ និងបានបន្តចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍រវាងខណ្ឌរដ្ឋបាលជលផល និងគណៈកម្មការសហគមន៍នេសាទលើកទី២ នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ ដែលបានរៀបចំដោយខណ្ឌរដ្ឋបាលជលផលក្រចេះនិងបន្តគាំទ្រដោយអង្គការWWF។

សហគមន៍នេសាទ**ខ្សាច់លាវ** មានទីតាំងស្ថិតនៅក្នុងភូមិខ្សាច់លាវ ឃុំអូរគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ ដែលមានសមាជិកសរុបចំនួន ៧២ នាក់ ស្រីចំនួន ០៦ នាក់ និងមានគណៈកម្មការចំនួន ០៩ នាក់ ស្រីចំនួន ០២ នាក់ ។ ក្នុងនោះចំនួនគ្រួសារសរុប មានចំនួន ១១៥ គ្រួសារ។.

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗ របស់ខ្លួន រួមមាន ៖

- បានបង្កើតសហគមន៍នេសាទ រៀបចំរចនាសម្ព័ន្ធ
- បានបង្កើតក្រុមល្បាតសហគមន៍នេសាទ
- បានធ្វើបង្គោលព្រំប្រទល់កន្លែងនេសាទសហគមន៍ចំនួន ២ កន្លែង
- បានបង្កើតធនាគារស្រូវ ធនាគារក្របី ក្រុមសន្សំប្រាក់ ផ្តល់អណ្តូងស្នប់ ពាងទឹក បង្គន់អនាម័យ ធុងចម្រោះអាងទឹក និងសាលារៀន
- កសិកម្មចម្រុះ ចិញ្ចឹមសត្វ ដាំបន្លែ ពេទ្យសត្វភូមិ គណៈកម្មការគ្រោះមហន្តរាយភូមិ
- សាងសង់សាលារៀន និងផ្ទះគ្រូ ដែលគាំទ្រដោយ**អង្គការ**CAA/Oxfam Australia ក្នុងឆ្នាំ១៩១៦
- បានបង្កើតសហគមន៍ព្រៃឈើ សហគមន៍កែឆ្នៃផ្តៅ ក្រុមសន្សំប្រាក់ ចែកពូជស្រូវ ដាំស្រូវគំរូ និងសួនបន្លែតាមគ្រួសារគាំទ្រដោយ **អង្គការ** CED
- បានទទួលកាណូតល្បាតចំនួន០១ គ្រឿង និងស្លាកសញ្ញាលើក្បូនឬស្សីចំនួន០៥ស្លាក ពីរដ្ឋបាលជលផល
- បានបង្កើតពេទ្យឆ្មបបុរាណ ពេទ្យសត្វ ផ្តល់អណ្តូងស្នប់ ពាងទឹក បង្រៀនពីការគ្រប់គ្រងគ្រោះមហន្តរាយ មានការពារទឹកជំនន់ ការពារអគ្គីភ័យ ការពារជម្ងឺ។ល។ គាំទ្រដោយ **ក្រុមភ្នាក់ងារសុខមាលភាព**
- ដោយផុតអាណតិសហគមន៍បានរៀបចំការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទឡើងវិញ
- រៀបចំឯកសារចុះបញ្ជីសហគមន៍នេសាទជាផ្លូវការ
- រៀបចំឯកសារចុះកិច្ចព្រមព្រៀង ផែនការគ្រប់គ្រងសហគមន៍នេសាទដែលទទួលស្គាល់ដោយថ្នាក់ជាតិ....ល
- បញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ
- លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង (រៀបចំធ្វើផែនទី កំណត់ដែននេសាទឡើងវិញ)
- បានទិញទូកកាណូតមួយគ្រឿង អាវពោងចំនួន១០ អាវភ្លៀងចំនួន៥ និងពិលបំភ្លឺពេលយប់ចំនួន២
- បានរៀបចំក្រុមល្បាត និងផែនការចុះល្បាតប្រចាំខែ

- បានធ្វើក្បូនស្លាកសញ្ញាបណ្តែតទឹកសម្គាល់កន្លែងអភិរក្សចំនួន២
- បានធ្វើគម្រោងការតាមដានផលចាប់ត្រីប្រចាំថ្ងៃជាប្រចាំ
  គាំទ្រដោយអង្គការ WWF ។

នៅមុនពេលបង្កើតសហគមន៍នេសាទ និងចន្លោះពេលដែលផុតអាណត្តិ បទល្មើសនេសាទតែងតែកើតមាននៅក្នុងសហគមន៍នេសាទដែលបណ្តាលឱ្យធនធានជលផលមានការថយចុះជាលំដាប់។ ប៉ុន្តែបន្ទាប់ពីបានបង្កើតសហគមន៍មកគណៈកម្មការសហគមន៍បានសហការជាមួយប៉ូលីសប៉ុស្តិ៍ អាជ្ញាធរភូមិ ឃុំ ស្រុក រដ្ឋបាលជលផល និងឆ្នាំទន្លេចុះល្បាត និងបង្ក្រាបបទល្មើសធ្វើឱ្យបទល្មើសនេសាទមានការថយចុះ និងធនធានជលផលមានការកើនឡើងវិញ ។

ទន្ទឹមនឹងនេះ ក៏នៅមានបទល្មើសនេសាទពីអ្នកខាងក្រៅសហគមន៍នេសាទលួចធ្វើនេសាទនៅកន្លែងអភិរក្សជាពិសេសនៅពេលយប់។ ដោយសហគមន៍នេសាទមានការខ្វះខាតប្រេងសម្រាប់ចាក់កាណូតចុះយាមល្បាតឱ្យបានទៀងទាត់ ខ្វះស្នាក់ការសម្រាប់បំពេញការងារ ម៉្យាងវិញទៀតគណៈកម្មការសហគមន៍នេសាទមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការដឹកនាំសហគមន៍នេសាទ ហើយការយល់ដឹងរបស់សមាជិកសហគមន៍នៅមានកម្រិត និងការចូលរួមការងារសហគមន៍នេសាទមិនទាន់បានសស្រាក់សស្រាំផងដែរ ។

## ២-អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក -ប្រជាសាស្ត្រ

- ចំនួនប្រជាពលរដ្ឋសរុបនៅក្នុងសហគមន៍មានចំនួន ៥៨៧នាក់ ប្រុសចំនួន ២៨៩នាក់ និងស្រីចំនួន ២៩៨នាក់ ក្នុងនោះជនជាតិដើមភាគតិចគឺគួយមាន៦០% ខ្មែរ៤០%
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ១២ នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន ០៥ នាក់ ស្រី០១នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ១៣ នាក់ ស្រី០៩នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន ១០នាក់ ស្រី០៤នាក់
- ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមាន ១០ នាក់ ស្រី០៧នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍នេសាទជាអ្នកកាន់សាសនាព្រះពុទ្ធ ១០០%
- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរមានចំនួន៤៥% កំរិតថ្នាក់បឋមសិក្សាចំនួន៤៥% និងមធ្យមសិក្សាមានចំនួន១០% និងកំរិតថ្នាក់ឧត្តមសិក្សា ០០ នាក់ ។

### ខ-មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន៖

- ធ្វើស្រូវវស្សា ចំនួន ៥៧ គ្រួសារ
- ធ្វើចំការចំនួន ៤៥ គ្រួសារ
- ធ្វើនេសាទលក្ខណៈគ្រួសារចំនួន ១០០ គ្រួសារ
- ដាំបន្លែជាលក្ខណៈគ្រួសារមានចំនួន ៥៥ គ្រួសារ
- ធ្វើជាងផ្ទះ ចំនួន ០៤ នាក់
- ធ្វើជាងទូកចំនួន ០៤ នាក់

- ផ្ញើកម្មករនៅពេលទំនេរពីការងារធ្វើស្រែចំនួន ១០ %
- លក់ដូរចំនួន ១២ គ្រួសារ ។

## ៣-កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងនេសាទសហគមន៍

### ក-ទីតាំង

កន្លែងនេសាទសហគមន៍ខ្សាច់លាវ ស្ថិតនៅតាមដងទន្លេមេគង្គលើមានទំហំ ៨៥៣ហិកតា និងមាននិយាមការដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

មានព្រំប្រទល់៖

-ខាងជើងទល់នឹងភូមិអូរម្រះ

-ខាងត្បូងទល់នឹងភូមិកោះខ្មែរ

-ខាងកើតទល់នឹងភូមិអូរព្រះ

-ខាងលិចទល់នឹងភូមិកំពង់រទេះ ឃុំបឹងចារ ។

### ខ-ដែននេសាទ

កន្លែងនេសាទសហគមន៍**ខ្សាច់លាវ** ស្ថិតនៅតាមដងទន្លេមេគង្គ ដែលមានព្រៃលិចទឹកដុះរាយ នៅតាមមាត់ច្រាំងទន្លេ នៅតាមកោះ និងមានអន្លង់ត្រីចំនួន ០៣ អន្លង់ គឺ៖

១. អន្លង់កណ្តុរ១០០

២. អន្លង់ក្រែង

៣. អន្លង់សម្រង ។

### គ-តំបន់ដែលបានបង្កើតកន្លែងអភិរក្ស៖

- អន្លង់កណ្តុរ១០០ មានទំហំ ១៥១.៧៧ ហិកតា (សម្រាប់អភិរក្សត្រីមេពូជ)
- អន្លង់ក្រែងមានទំហំ ៩៧.៩៣ ហិកតា (សម្រាប់អភិរក្សត្រីមេពូជ)។

### ឃ-ធនធានជលផល

- ប្រភេទត្រី ៖

ឆ្តោកភ្លើង ឆ្តោកក្តា ឆ្លាំង ត្រសក់ ប្រា គល់រាំង គល់ព្រិច រ៉ស់ ក្អែកពូក រៀល ក្អែកខ្មៅ ប្រាកណ្តុរ ឈ្វាត ក្តីគ្រំ កន្ទួនដៃ ខ្យាក្រហម ខ្យាខ្មៅ ត្រនេល អំបូង ព្រលូង រលកស ឆ្ពិន កាហែ ច្រកែង អណ្តែង រមាស ក្លាំងហាយ កែស ពោរ ខ្លា ឆ្លូញ ខ្ទីង ដំរី កញ្ចុះក្តោង កញ្ចុះជរ កញ្ចុះប៉ាវ៉ា ចង្វារមូល ចង្វារភ្លៀង ស្លឹកឬស្សី បង្គួយ ខ្មាន់ កាំនិម ឆ្មុកដប កំពីងដូង បួសចេក ខ្សាន ក្រាញ់ ផ្ទោង ស្លាត ស្រកាក្តាម ព្រួល ប្រម៉ា ក្រឹម ពុកមាត់ឆ្មារ ដងដាវ ក្អុក ក្រពតអណ្តាតឆ្កែ កញ្រ្ជូក ឆ្តោរ ក្រពាត់ សណ្តាយ ក្រាយ អំពិលទុំ សារិកាកែវ កន្ត្រប់ កន្ត្រង់ប្រេង កំភ្លាញ កន្ធរ ផ្ទក់ស្នូក់ ប៉ាវ៉ា ប៉ាស៊ីអ៊ី រាហូ។

-ប្រភេទវារីសត្វ ៖

បង្កង កំពិស អណ្តើក ត្រកួត កន្ធាយ ល្មិច ខ្យង បបែល ពស់ព្រលិត សម្លាប់កង្កែប កង្កែប ក្តាម ខ្ចៅលាស គ្រំ ។

-ប្រភេទថនិកសត្វទឹក ៖

ផ្សោតក្បាលត្រឡោក ។

-ប្រភេទព្រៃលិចទឹក ៖

ដើមត្រស់ រាំង រៃ ទន្លា អណ្ដែង អញ្ចេង អញ្ចៃ ស្រូល រៃ ញរទឹក ស្ដី ព្រីង ខ្ទឹមទឹក ទ្រយឹងទឹក ឃ្នាទឹក ចេកទុំ វល្លិល្អាន វល្លិត្រដិត ច្រកែងក្ងួយ ស្ពៃទឹក ផ្ទង ក្ដុល ឃ្លេ បន្លាយួន ល្វា ជ្រោយ ស្រួយ ក្របៅ បបុស សង្កែ អន្សែង សណ្ដាន់ ស្បូវ មាន គ្រែង ស្លត ក្រ ថ្មោង ព្រីងទឹក។

## ៤-ការធ្វើនេសាទ

### ក-អ្នកនេសាទ

-អ្នកនេសាទជាសមាជិកសហគមន៍ ចំនួន ៧២ នាក់ ស្រី ០៦ នាក់

-អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ នៅក្នុងសហគមន៍មានចំនួន ២០ នាក់ ស្រី ០៥ នាក់

-ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីខាងក្រៅសហគមន៍មានចំនួន ១៦ នាក់ ស្រី ០៨ នាក់។

### ខ.ឧបករណ៍នេសាទ

-ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ៖

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|
| សំណាញ់ | វង់ | ៥០ | ប្រវែង ៥ ម ក្រឡា ០,០១៥ ម | មករា ដល់ ឧសភា |
| លប | លប | ៦០ | មុខ ០,៨ម បណ្ដោយ ១,២ ម | មករា ដល់ មិថុនា |
| ចាន់ | ចាន់ | ២០ | មុខ ០,៦ ម កម្ពស់ ១,៦ \ ម | មិថុនា ដល់ ធ្នូ |
| សន្ទូចរនង | សាង(៥០ផ្លែ) | ២៥ | ផ្លែលេខ ០៩-១២ | មេសា ដល់ ធ្នូ |
| មង | ត្បូង (៤០ម៉ែត្រ) | ៨០ | ០,០២ ម- ០,០៩ ម | មករា ដល់ ធ្នូ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកចែវ | ០២ ទូក | ១០០-២០០ គីឡូក្រាម | |
| ទូកមានម៉ាស៊ីន | ៤៥ គ្រឿង | ១០០-៦០០ គីឡូក្រាម | ៥ សេះ - ១៨ សេះ |

-ឧបករណ៍នេសាទ និងទូកកាណូតរបស់អ្នកនៅក្នុងតំបន់តែមិនមែនជាសមាជិកសហគមន៍នេសាទ៖

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|
| ប៉ោង | ប៉ោង | ២០ | មុខ ០,៤ ម បណ្ដោយ ០,៩ ម | មិថុនា ដល់ ធ្នូ |
| មង | ត្បូង (៤០ម៉ែត្រ) | ៤០ | ០,៩ ម- ០,១៣ ម | មករា ដល់ ធ្នូ |
| សន្ទូចរនង | សាង(១០០ផ្លែ) | ៤០ | ផ្លែលេខ ៩-១២ | មករា ដល់ មិថុនា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ៨ គ្រឿង | ៦០០ គីឡូក្រាម | ១៣ សេះ- ១៨ សេះ |

-ឧបករណ៍នេសាទ និងទូកកាណូតរបស់អ្នក មិនមែនជាសមាជិកសហគមន៍ដែលមកពីខាងក្រៅសហគមន៍នេសាទ៖

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|
| ប៉ោង | ប៉ោង | ២០ | មុខ ០,៤ ម បណ្ដោយ ០,៩ ម | មិថុនា ដល់ ធ្នូ |
| មង | ត្បូង (៤០ម៉ែត្រ) | ៦០ | ០,៩ ម- ០,១៣ ម | មករា ដល់ ធ្នូ |
| សន្ទូចរនង | សាង(១០០ផ្លែ) | ៣០ | ផ្លែលេខ ៩-១២ | មករា ដល់ មិថុនា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ១៥ គ្រឿង | ៥០០ គីឡូក្រាម | ៥ សេះ- ១៨ សេះ |

គ-ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ(គិតជាគីឡូក្រាម) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រីចម្រុះ | ៥៥ គីឡូក្រាម | ៨៥គីឡូក្រាម | ១៤០ គីឡូក្រាម |

## ៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ

### ក-ទស្សនវិស័យ

សហគមន៍នេសាទខ្សាច់លាវ មានទស្សនវិស័យរួមចំណែកគ្រប់គ្រងធនធានជលផលប្រកបដោយសមធម៌ និងចីរភាពដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ-គោលបំណង

-ចូលរួមគ្រប់គ្រងកន្លែងនេសាទសហគមន៍ខ្សាច់លាវ

-ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌

-ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍចម្រុះដោយមានការចូលរួម

-ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនិងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ។

## គ-ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទ ដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។

គោលបំណង ៖ - ដើម្បីកំណត់ចំនួនឧបករណ៍នេសាទក្នុងសហគមន៍ឱ្យបានសមស្រប ជៀសវាងការធ្វើនេសាទហួសកម្រិតផលស្តុក ។

- ដើម្បីឱ្យសមាជិកសហគមន៍នេសាទ និងអ្នកនេសាទមកពីក្រៅសហគមន៍ធ្វើនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ទីតាំង និងពេលវេលានេសាទ

ផលរំពឹងទុក ៖ - ត្រីមេពូជ និងសត្វផ្សោតត្រូវបានការពារ និងមានការកើនឡើងនៅក្នុងសហគមន៍

- ការនេសាទនៅកន្លែងអភិរក្ស និងឧបករណ៍នេសាទខុសច្បាប់ត្រូវបានហាមឃាត់។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | សកម្មភាព | គម្រោងថវិកា(ដុល្លា) | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេង |
|---|---|---|---|---|---|---|---|
| | | | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| នៅតាមដងទន្លេមេគង្គនៅខាងក្រៅអន្លង់អភិរក្សសហគមន៍ | ១.១-ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត ទំហំ ពេលវេលានិងទីកន្លែងនេសាទនិងប្រភេទឧបករណ៍នេសាទហាមឃាត់<br>១.២-ដាក់បង្ហាញស្លាកសញ្ញាពីប្រភេទឧបករណ៍នេសាទ<br>១.៣-ចុះត្រួតពិនិត្យការធ្វើនេសាទគ្រប់ប្រភេទ | ២០០/ឆ្នាំ | មករា ដល់មិថុនា | សំណាញ់ | ប្រវែង ៥ ម ក្រឡា ០,០២ ម | ៥០ វង់ | |
| | | | | លប | មុខ ០,៨ម បណ្តោយ ១,២ ម | ៦០ លប | |
| | | | មិថុនាដល់ធ្នូ | ចាន់ | មុខ ០,៦ ម កម្ពស់ ១,២ ម | ២០ ចាន់ | |
| | | | មករា ដល់ ធ្នូ | សន្ទូចរនង | ផ្លែលេខ ១០-១២ | ២៥ សាង | សាង(១០០ ផ្លែ) |
| | | | | មង | ក្រឡា ០,០២ ម- ០,០៩ ម | ៨០ ត្បូង | ត្បូង (៥០ម៉ែត្រ) |

គ២-ផែនការការពារកន្លែងអភិរក្សសហគមន៍

គោលបំណង ៖ - ដើម្បីបង្ហាញអ្នកនេសាទក្នុងសហគមន៍ និងក្រៅសហគមន៍ឱ្យបានដឹងពីទីតាំងកន្លែងអភិរក្សត្រីមេពូជ និងអភិរក្សសត្វផ្សោត
- ដើម្បីការពារត្រីមេពូជ និងសត្វផ្សោតនៅក្នុងសហគមន៍។

ផលរំពឹងទុក ៖ - ត្រីមេពូជ និងសត្វផ្សោតត្រូវបានការពារ និងមានការកើនឡើងនៅក្នុងសហគមន៍
- ការនេសាទនៅកន្លែងអភិរក្សត្រូវបានហាមឃាត់។

ផែនការការពារកន្លែងអភិរក្សសហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ឈ្មោះដែន នេសាទ | ទំហំ (ហ.ត) | សកម្មភាព | គម្រោង ថវិកា(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| អន្លង់កណ្តុរ១០០ | ១៥១.៧៧ | - សាងសង់ផែបណ្តែតទឹកដាក់ក្បែរ អន្លង់អភិរក្សទំហំ ៦ម x៩ម | ១០០០ | ០១.០១.២០១៨ | ៣០.០៦.២០២០ | ក្បូនឬស្សីត្រូវដាក់រៀងរាល់ឆ្នាំ រយៈពេល ៣ ឆ្នាំ |
| អន្លង់ត្រែង | ៩៧.៩៣ | - ដាក់ក្បូនឬស្សីស្លាកសញ្ញាសំគាល់កន្លែងអភិរក្សចំនួន ១០ ស្លាក<br>- បោះបង្គោលព្រំប្រទល់កន្លែងអភិរក្សចំនួន ៤ បង្គោល | ៤០០ | ០១.០២.២០១៨ | ៣០.០២.២០២០ | |

គ៣-ផែនការពង្រឹងការគ្រប់គ្រងសហគមន៍នេសាទ

គោលបំណង ៖ - ដើម្បីឱ្យគណៈកម្មការ និងក្រុមល្បាតសហគមន៍នេសាទមានឧបករណ៍ សំភារៈគ្រប់គ្រាន់ក្នុងការចុះល្បាត និងទប់ស្កាត់បទល្មើសនេសាទគ្រប់ប្រភេទ

- ដើម្បីឱ្យសហគមន៍នេសាទមានទីស្នាក់ការដើម្បីធ្វើការងាររដ្ឋបាល ប្រជុំការងារ ការទំនាក់ទំនង និងរក្សាទុកសំភារៈ និងឯកសារផ្សេងៗ ។

ផលរំពឹងទុក ៖ - គណៈកម្មការ និងក្រុមល្បាតសហគមន៍នេសាទអាចអនុវត្តន៍ការងារប្រកបដោយប្រសិទ្ធភាពខ្ពស់

- សហគមន៍នេសាទមានទីស្នាក់ការសម្រាប់ទំនាក់ទំនងការងារ និងប្រចាំការ។

ផែនការពង្រឹងការគ្រប់គ្រងសហគមន៍នេសាទ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| សកម្មភាព | តម្រូវការសំភារៈ | ចំនួន | គម្រោងថវិកា(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ៣.១--ពង្រឹងការងារល្បាតក្នុងសហគមន៍ | អាវពោង | ១០ អាវ | ១,៥០០ | ០១.០១.២០១៨ | ៣០.០១.២០២០ | |
| | អាវភ្លៀង | ១០ អាវ | | | | |
| | ភ្លើងហ្វាដាក់តាមកាណូត | ៤ | | | | |
| | វិទ្យុទាក់ទង | ៤ | | | | |
| | អាគុយ | ១ | | | | |
| | ឯកសណ្ឋានអាវ និងមួកសម្រាប់ល្បាត | ២០ | | | | |
| | ស្បែកជើងកវែង | ២០ | | | | |
| | ម៉ាស៊ីនថត | ១ | | | | |
| | អង្រឹង | ២០ | | | | |
| ៣.២-សាងសង់ទីស្នាក់ការសហគមន៍ | ទីស្នាក់ការទំហំ ៤មX៦ម | ១ | ២.០០០ | ០១.១២.២០១៨ | ៣០.១២.២០២០ | |
| ៣.៣-កាណូតម៉ាស៊ីន ១៣ សេះ | ទូកទំហំ ៩ ម X ០,៨ ម | ១ | ១,២០០ | ០១.០១.២០១៨ | ៣០.០១.២០២០ | |

គ៤-ផែនការប្រជុំគណៈកម្មការ និងក្រុមល្បាត

គោលបំណង ៖ - ដើម្បីឱ្យគណៈកម្មការ និងក្រុមល្បាតសហគមន៍នេសាទ ប្រជុំបូកសរុបលទ្ធផលដែលបានអនុវត្តន៍ លើកបញ្ហាផ្សេងដែលបានជួបប្រទះ លើកផែនការអនុវត្តន៍បន្ត

- ធ្វើរបាយការណ៍ពីលទ្ធផលការងារ ការលំបាក ការងាយស្រួល ទៅអាជ្ញាធរឃុំ ស្រុក ខណ្ឌរដ្ឋបាលជលផលដើម្បីជួយដោះស្រាយ ។

ផលរំពឹងទុក ៖ - សហគមន៍នេសាទអាចដំណើរការគ្រប់គ្រងមានប្រសិទ្ធភាព

- បញ្ហាលំបាកផ្សេងៗដែលកើតមាននៅក្នុងសហគមន៍នេសាទត្រូវបានដោះស្រាយ និងលើកទិសដៅអនុវត្តន៍ទៅថ្ងៃមុខបន្ត ។

ផែនការប្រជុំគណៈកម្មការ និងក្រុមល្បាតត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| សកម្មភាព | អ្នកចូលរួម | គម្រោងថវិកា(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|
| ៤.១-ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍ | -គណៈកម្មការសហគមន៍នេសាទ<br>-ក្រុមល្បាតសហគមន៍<br>- ប៉ូលីសប៉ុស្តិ៍<br>- ឆ្មាំទន្លេ | ២០/ខែ<br>១ឆ្នាំ=២០X១២ = ២៤០ | ២០.០៦.២០១៨ | ២០.១២.២០២០ | ប្រជុំរៀងរាល់ខែ រយៈពេល ៣ ឆ្នាំ |
| ៤.២-រៀបចំមហាសន្និបាតសហគមន៍នេសាទប្រចាំឆ្នាំ | -គណៈកម្មការសហគមន៍នេសាទ<br>-ក្រុមល្បាតសហគមន៍<br>- ប៉ូលីសប៉ុស្តិ៍<br>- ឆ្មាំទន្លេ<br>- សមាជិកសហគមន៍<br>-អាជ្ញាធរមូលដ្ឋាន<br>-រដ្ឋបាលជលផល | ៦០០/ឆ្នាំ | ១២.០១.២០១៨ | ១២.០២.២០២០ | មួយឆ្នាំម្តង |
| ៤.៣-រៀបចំផែនការគ្រប់គ្រងឡើងវិញ | | ៥០០/ឆ្នាំ | ២៥.០៥.២០១៨ | ៣០.១២.២០២០ | ៣ឆ្នាំម្តង |

គ៥-ផែនការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ

គោលបំណង ៖ - ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសនេសាទក្នុងសហគមន៍ឱ្យមានប្រសិទ្ធភាព
- សហគមន៍នេសាទមានមធ្យោបាយសម្រាប់ទប់ស្កាត់បទល្មើស ។

ផលរំពឹងទុក ៖ - សហគមន៍នេសាទមានការយាមល្បាតទៀងទាត់
- បទល្មើសនេសាទនៅក្នុងសហគមន៍ត្រូវបានថយចុះ ។

ផែនការចុះទប់ស្កាត់បទល្មើសនេសាទ ត្រូវបានរៀបចំដូចខាងក្រោម ៖

| សកម្មភាព | តម្រូវការសំភារៈ | គម្រោងថវិកា (ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ៥.១-ចុះល្បាតចំនួន ០៨ ដង ក្នុង១ ខែនៅរដូវប្រាំង (០៨ ដងx៦ខែX ៥លីត្រ = ២៤០លីត្រ) | - ប្រេងសាំងចំនួន ២៤០ លីត្រ<br>- ប្រេងម៉ាស៊ីន ចំនួន ៨ លីត្រ | ៣៤០ | -គណៈកម្មការសហគមន៍នេសាទ<br>-ក្រុមល្បាតសហគមន៍<br>- ប៉ូលីសប៉ុស្តិ៍<br>- ឆ្មាំទន្លេ | ០១.០៦.២០១៨ | ៣០.១១.២០២០ | ល្បាតរៀងរាល់ឆ្នាំ រយៈពេល ៣ ឆ្នាំ |
| ៥.២-ចុះល្បាតចំនួន ៥ ដងក្នុង១ ខែ នៅរដូវវស្សា (៥ ដងx៦ខែ X ៥លីត្រ = ១៥០ លីត្រ) | - ប្រេងសាំងចំនួន ១៥០ លីត្រ<br>- ប្រេងម៉ាស៊ីន ចំនួន ៤ លីត្រ | ២០៨ | | ០១.១២.២០១៨ | ៣០.០៥.២០២០ | ល្បាតរៀងរាល់ឆ្នាំ រយៈពេល ៣ ឆ្នាំ |

គ៦-ផែនការផ្សព្វផ្សាយ

គោលបំណង ៖ ដើម្បីឱ្យសមាជិកសហគមន៍នេសាទ អ្នកមិនមែនជាសមាជិកសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋានយល់ដឹងពីឯកសារផ្សេងៗ របស់សហគមន៍ និងប្រកាស អនុក្រឹត្យ និងច្បាប់ផ្សេងដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ។

ផលរំពឹងទុក ៖ សមាជិកសហគមន៍នេសាទ អ្នកមិនមែនជាសមាជិកសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋានមានការយល់ដឹងហើយចូលរួមគាំទ្រ និងអនុវត្តន៍ឱ្យមានប្រសិទ្ធភាព។

ផែនការផ្សព្វផ្សាយច្បាប់ជលផល ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| សកម្មភាព | តម្រូវការ | គម្រោងថវិកា(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ៦.១-ផ្សព្វផ្សាយអំពីលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | -ឯកសារផ្សព្វផ្សាយ<br>-គ្រូបង្គោល | ២៥០ | គណៈកម្មការ<br>អាជ្ញាធរមូលដ្ឋាន<br>ជំនាញជលផល<br>សមាជិកសហគមន៍នេសាទ | ០១.០៥.២០១៨ | ០១.០៦.២០២០ | ១ឆ្នាំម្តង |
| ៦.២-ផ្សព្វផ្សាយអំពីកិច្ចព្រមព្រៀង ប្រកាសស្តីពីការចុះបញ្ជីសហគមន៍នេសាទនិងផែនទីកន្លែងនេសាទសហគមន៍ | | ២៥០ | | ០១.០៥.២០១៨ | ០១.០៦.២០២០ | |
| ៦.៣-ផ្សព្វផ្សាយអំពីផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | | ២៥០ | | ០១.០៥.២០១៨ | ០១.០៦.២០២០ | |
| ៦.៤-ផ្សព្វផ្សាយអំពីច្បាប់ស្តីពីជលផល និងប្រកាសពាក់ព័ន្ធផ្សេងៗ | | ២៥០ | | ០១.០៥.២០១៨ | ០១.០៦.២០២០ | |
| ៦.៥-ផ្សព្វផ្សាយអំពីអនុក្រឹត្យតំបន់គ្រប់គ្រងនិងការពារសត្វផ្សោត និងបរិស្ថាន | | ២៥០ | | ០១.០៥.២០១៨ | ០១.០៦.២០២០ | |
| ៦.៦-ផ្សព្វផ្សាយជ្រើសរើសអ្នកចូលជាសមាជិកសហគមន៍នេសាទ | | ២៥០ | | ០១.១២.២០១៨ | ០១.០១.២០២០ | |

គ៧-ផែនការបណ្តុះបណ្តាល

គោលបំណង ៖ ផ្តល់ចំណេះដឹងពីការងាររដ្ឋបាល ការងារធ្វើផែនការ ការងារដឹកនាំ និងនីតិវិធីកសាងឯកសារនានាដល់គណៈកម្មការសហគមន៍នេសាទ។

លទ្ធផលរំពឹងទុក ៖ គណៈកម្មការសហគមន៍នេសាទមានសមត្ថភាពក្នុងការដឹកនាំ ការគ្រប់គ្រង និងការកសាងឯកសារសំណុំរឿងបទល្មើសជលផល។

ផែនការបណ្តុះបណ្តាលត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| សកម្មភាព | តម្រូវការ | គម្រោងថវិកា(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ៧.១-បណ្តុះបណ្តាលអំពីរបៀបសសេរកំណត់ហេតុ និងរបាយការណ៍ | -ឯកសារបណ្តុះបណ្តាល<br>-គ្រូបណ្តុះបណ្តាល | ៣៥០ | គណៈកម្មការ<br>អាជ្ញាធរមូលដ្ឋាន<br>ក្រុមល្បាត<br>មន្ត្រីជលផល | ០១.០១.២០១៨ | ០១.០២.២០២០ | |
| ៧.២-បណ្តុះបណ្តាលអំពីការធ្វើផែនការសកម្មភាពការងារ បេលា គណៈនេយ្យ | | ៣៥០ | | ០១.០១.២០១៨ | ០១.០២.២០២០ | |
| ៧.៣-បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | | ៣៥០ | | ០១.០១.២០១៨ | ០១.០២.២០២០ | |
| ៧.៤- ការអនុវត្តច្បាប់ និងការចុះយាមល្បាត | | ៣៥០ | | ០១.០១.២០១៨ | ០១.០២.២០២០ | |
| ៧.៥-បណ្តុះបណ្តាលអំពីនីតិវិធី និងការកសាងសំណុំរឿងបទល្មើសនេសាទបឋម | | ៣៥០ | | ០១.០១.២០១៨ | ០១.០២.២០២០ | |

គ៨- ផែនការចំណូលថវិកាទ្រទ្រង់សហគមន៍

គោលបំណង ៖ ដើម្បីប្រមូលថវិកាពីសមាជិកមកប្រើប្រាស់សម្រាប់ការងារគ្រប់គ្រងសហគមន៍។

លទ្ធផលរំពឹងទុក ៖ សហគមន៍នេសាទនឹងមានថវិកាមកទ្រទ្រង់ការងារគ្រប់គ្រងសហគមន៍នេសាទ។

ផែនការចំណូលថវិកាទ្រទ្រង់សហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ ចាប់បញ្ចប់ | ចំណូលសរុប (រៀល) | ផ្សេងៗ |
|---|---|---|---|---|---|
| ១១.១-ភាគទានពីសមាជិកសហគមន៍នេសាទដែលទើបនឹងចូលថ្មី | ប្រមូលភាគទានពីសមាជិកដែលចូលថ្មី | ០១.០១.២០១៨ | ០១.១២.២០២០ | ៣០០.០០០ | ២.០០០ រៀល/នាក់ |
| ១១.២-ភាគទានរបស់សមាជិកសហគមន៍នេសាទប្រចាំឆ្នាំ | ប្រមូលភាគទានប្រចាំឆ្នាំពីសមាជិក | ០១.១២.២០១៨ | ០១.១២.២០២០ | ៣០០.០០០ | ២.០០០ រៀល/នាក់ រយៈពេល៣ឆ្នាំ |
| ១១.៣- ធ្វើនេសាទសិប្បកម្មដើម្បីរកចំណូលគាំទ្រសហគមន៍នេសាទ | ដាក់ពាក្យស្នើសុំអន្លង់មិនអភិរក្ស ធ្វើនេសាទសិប្បកម្មសម្រាប់រកប្រាក់ចំណូលគាំទ្រដល់សហគមន៍នេសាទ | ០១.០២.២០១៨ | ០១.០៣.២០២០ | ៦០០.០០០ | កិច្ចគាំទ្រពីស្ថាប័នពាក់ព័ន្ធ |
| ១១.៤-ហិបភាគទានរៃអង្គាសរកចំណូលគាំទ្រសហគមន៍នេសាទ | ធ្វើហិបសង្កសីរបស់សហគមន៍ដាក់នៅតាមវត្ត ពិធីបុណ្យ បង្កើតគណៈកម្មការគ្រប់គ្រងហិបភាគទាន | ០១.០២.២០១៨ | ០១.០៣.២០២០ | ៥០០.០០០ | |
| ១១.៥-ភាគទានពីដែនបណ្តៃទឹកកំសាន្ត | ធ្វើដែនបណ្តៃទឹកកំសាន្តទាក់ទាញភ្ញៀវទេសចរណ៍ | ០១.០២.២០១៨ | ០១.០៣.២០២០ | ៥០០.០០០ | កិច្ចគាំទ្រពីស្ថាប័នពាក់ព័ន្ធ |

គ៩-ផែនការកែលម្អដែននេសាទ

សំគាល់ ៖ ដោយកន្លែងនេសាទសហគមន៍ខ្សាច់លាវស្ថិតនៅតាមដងទន្លេមេគង្គពុំមានផែនការត្រូវកែលម្អឡើយ ។

| ឈ្មោះដែននេសាទ | ទំហំ(ហ.ត) | ទំហំដែលត្រូវកែលម្អ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | | | |

គ១០-ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

កំណត់សំគាល់ ៖ ទីតាំងសហគមន៍ស្ថិតនៅក្នុងតំបន់ស្នូលទី៣ ក្នុងឃុំអូរគ្រៀង ដែលកំណត់ដោយអនុក្រឹត្យលេខ ១៥៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០១២ ស្តីពីការបង្កើតតំបន់គ្រប់គ្រង និងការពារសត្វផ្សោតទន្លេមេគង្គ ពុំអនុញ្ញាតឱ្យធ្វើ វារីវប្បកម្មបែ ឬសិងក្នុងតំបន់ស្នូលនៅរដូវប្រាំងម៉្យាងវិញទៀតនៅតំបន់នេះ ជាប្រភេទដីមិនគត់ទឹកនៅរដូវប្រាំង ។

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រី | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| | | | | | |

គ១១-ផែនការមុខរបរចិញ្ចឹមជីវិត

គោលបំណង ៖ ដើម្បីធ្វើឱ្យគណៈកម្មការនិងសមាជិកសហគមន៍នេសាទ ទទួលបានប្រាក់ចំណូល និងជីវភាពបានប្រសើរឡើងតាមរយៈការអភិវឌ្ឍចម្រុះដោយមានការចូលរួម ដើម្បីឈានដល់ការកាត់បន្ថយភាពក្រីក្រ និងការនេសាទក្នុងតំបន់អភិរក្សសត្វផ្សោត។

លទ្ធផលរំពឹងទុក៖ គណៈកម្មការសហគមន៍នេសាទនិងសមាជិកមានមុខរបរ ទទួលបានប្រាក់ចំនូល ជីវភាពត្រូវបានប្រសើរឡើង និងការធ្វើនេសាទនៅក្នុងតំបន់ស្នូលជាតំបន់អភិរក្សសត្វផ្សោត ត្រូវបានកាត់បន្ថយ ។

ផែនការបង្កើតមុខរបរចម្រុះ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| សកម្មភាព | តម្រូវការ | គម្រោងថវិកា(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១០.១-បណ្តុះបណ្តាលវគ្គចិញ្ចឹមជ្រូក មាន់ ទា | -គ្រូបណ្តុះបណ្តាល<br>- ឯកសារបណ្តុះបណ្តាល<br>- ថវិកាទុន | ៤០០០ | គ្រូបណ្តុះបណ្តាល គណៈកម្មការ និងសមាជិសហគមន៍ ដែលជាក្រុមគោដៅពី១៥ទៅ២០នាក់ | ០១.០១.២០១៨ | ០១.០២.២០២០ | |
| ១០.២-បណ្តុះបណ្តាលក្រុមបណ្តុះផ្សិតចំបើង | | ១៥០០ | | ០១.០១.២០១៨ | ០១.០២.២០២០ | |
| ១០.៣-បណ្តុះបណ្តាលក្រុមសន្សំប្រាក់ ឬក្រុមជួយខ្លួនឯង | | ២០០០ | | ០១.០១.២០១៨ | ០១.០២.២០២០ | |

## ឃ.យុទ្ធសាស្ត្រ

ដើម្បីអនុវត្តន៍ផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំ ដូចខាងក្រោម ៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តន៍តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការ រួមមានៈសមាជិកគណៈកម្មការសហគមន៍នេសាទចាស់ទុំ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អៗជាពិសេសបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណា ដែលទាក់ទងនិងបច្ចេកទេសជលផលដូចជាការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែង អភិរក្ស ព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រៃក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បី ទទួល បានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តន៍ផែនការ
- រៀបចំផែនការ អនុវត្តន៍ផែនការតាមដំណាក់កាលនិមួយៗដោយជាក់លាក់ និងផែនការសកម្មភាពប្រចាំឆ្នាំ
- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិការ និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការណ៍ចំពោះអ្នកនេសាទមកពីខាងក្រៅសហគមន៍
- ពង្រឹងសម្ថភាពបច្ចេកទេស និង គ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តន៍ផែនការ
- បញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍឃុំ ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ខ្សាច់លាវ រយៈពេល ៣ ឆ្នាំ (២០១៨ ដល់ ២០២០)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ១.១-ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត ទំហំ ពេលវេលានិងទីកន្លែងនេសាទនិងប្រភេទឧបករណ៍នេសាទហាមឃាត់ | - ត្រីមេពូជ និងផ្សោតត្រូវបានការពារ និងមានការកើនឡើងនៅក្នុងសហគមន៍<br>- ការនេសាទនៅកន្លែងអភិរក្ស និងឧបករណ៍នេសាទខុសច្បាប់ត្រូវបានហាមឃាត់។ | ៤០០/ឆ្នាំ | អង្គការដៃគូរដ្ឋបាលជលផលចរិកាសហគមន៍ | ០១.០៥.២០១៨ | ៣០.០១.២០២០ | |
| | ១.២-ដាក់បង្ហាញស្លាកសញ្ញាពីប្រភេទឧបករណ៍នេសាទ | | | | ០១.០១.២០១៨ | ៣០.០១.២០២០ | |
| | ១.៣-ចុះត្រួតពិនិត្យការធ្វើនេសាទគ្រប់ប្រភេទ | | | | ០១.០៦.២០១៨ | ៣០.១២.២០២០ | |
| គ២-ផែនការការពារកន្លែងអភិរក្សសហគមន៍ | ២.១-ដាក់ក្បូនឬស្សីស្លាកសញ្ញាសំគាល់ កន្លែងអភិរក្សចំនួន ៥ ស្លាក | - ត្រីមេពូជ និងផ្សោតត្រូវបានការពារ និងមានការកើនឡើងនៅក្នុងសហគមន៍<br>- ការនេសាទនៅកន្លែងអភិរក្សត្រូវបានហាមឃាត់។ | ៥០០ | អង្គការដៃគូរដ្ឋបាលជលផល | ០១.០១.២០១៨ | ៣០.០៦.២០២០ | រៀងរាល់ឆ្នាំ |
| | ២.២-បោះបង្គោលព្រំប្រទល់កន្លែងអភិរក្សចំនួន ៤ បង្គោល | | | | ០១.០២.២០១៨ | ៣០.០២.២០២០ | |
| គ៣-ផែនការពង្រឹងការគ្រប់គ្រងសហគមន៍នេសាទ | ៣.១-ពង្រឹងការងារល្បាតក្នុងសហគមន៍ | - គណៈកម្មការ និងក្រុមល្បាតសហគមន៍នេសាទអាចអនុវត្តន៍ការងារប្រកបដោយប្រសិទ្ធភាពខ្ពស់<br>- សហគមន៍នេសាទមានស្នាក់ការសម្រាប់ទំនាក់ទំនងការងារនិងប្រចាំការ។ | ១,៥០០ | អង្គការដៃគូរដ្ឋបាលជលផល | ០១.០១.២០១៨ | ៣០.០៦.២០២០ | |
| | ៣.២-សាងសង់ទីស្នាក់ការសហគមន៍ | | ២.០០០ | | ០១.០១.២០១៨ | ៣០.០៦.២០២០ | |
| | ៣.៣-កាណូតម៉ាស៊ីន ១៣ សេះ | | ១,២០០ | | ០១.០១.២០២០ | ៣០.១២.២០២០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| គ៤-ផែនការប្រជុំគណៈកម្មការនិងក្រុមល្បាត | ៤.១-ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍ | -សហគមន៍នេសាទអាចដំណើរការគ្រប់គ្រងមានប្រសិទ្ធភាព<br>-បញ្ហាលំបាកផ្សេងដែលកើតមាននៅក្នុងសហគមន៍នេសាទត្រូវបានដោះស្រាយ និងលើកទិសដៅអនុវត្តន៍ ។ | ៣០០ | អង្គការដៃគូ រដ្ឋបាលជលផល ថវិកាសហគមន៍ | ២២.០៤.២០១៨ | ២២.១២.២០២០ | ប្រជុំរៀងរាល់ខែ |
| | ៤.២-រៀបចំមហាសន្និបាតសហគមន៍នេសាទប្រចាំឆ្នាំ | | ៦០០ | | ១២.០១.២០១៨ | ១២.០១.២០២០ | មួយឆ្នាំម្តង |
| | ៤.៣-រៀបចំផែនការគ្រប់គ្រងឡើងវិញ | | ៥០០ | | ២៥.០៧.២០១៨ | ៣០.១២.២០២០ | បីឆ្នាំម្តង |
| | ៤.៤.ប្រជុំបណ្តាញ | | ២០០ | | ២៥.០៥.២០១៨ | ៣០.១២.២០២០ | |
| គ៥-ផែនការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ | ៥.១-ចុះល្បាតចំនួន ០៨ ដង ក្នុង១ខែនៅរដូវប្រាំង | -សហគមន៍នេសាទមានការយាមល្បាតទៀងទាត់<br>-បទល្មើសនេសាទនៅក្នុងសហគមន៍ត្រូវបានថយចុះ។ | ៣៤០ | អង្គការដៃគូ រដ្ឋបាលជលផល | ០១.០៦.២០១៨ | ៣០.១១.២០២០ | |
| | ៥.២-ចុះល្បាតចំនួន ៥ ដងក្នុង១ ខែនៅរដូវវស្សា | | ២០៨ | | ០១.១២.២០១៨ | ៣០.០៥.២០២០ | |
| គ៦-ផែនការផ្សព្វផ្សាយ | ៦.១-ផ្សព្វផ្សាយអំពីលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងហគមន៍នេសាទ | សមាជិកសហគមន៍នេសាទ អ្នកមិនមែនជាសមាជិកសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន យល់ដឹងហើយចូលរួមគាំទ្រនិងអនុវត្តន៍ឱ្យមានប្រសិទ្ធភាព។ | ២៥០ | អង្គការដៃគូ រដ្ឋបាលជលផល | ០១.០៥.២០១៨ | ០១.០៦.២០២០ | |
| | ៦.២-ផ្សព្វផ្សាយអំពីកិច្ចព្រមព្រៀងប្រកាសស្តីពីការចុះបញ្ជីសហគមន៍និងផែនទីកន្លែងនេសាទសហគមន៍ | | ២៥០ | | ០១.០៥.២០១៨ | ០១.០៦.២០២០ | |
| | ៦.៣-ផ្សព្វផ្សាយអំពីផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | | ២៥០ | | ០១.០៥.២០១៨ | ០១.០៦.២០២០ | |
| | ៦.៤-ផ្សព្វផ្សាយអំពីច្បាប់ស្តីពីជលផល និងប្រកាសពាក់ព័ន្ធផ្សេងៗ | | ២៥០ | | ០១.០៥.២០១៨ | ០១.០៦.២០២០ | |
| | ៦.៥-ផ្សព្វផ្សាយអំពីអនុក្រឹត្យតំបន់គ្រប់គ្រងនិងការពារសត្វផ្សោតនិងបរិស្ថាន | | ២៥០ | | ០១.០៥.២០១៨ | ០១.០៦.២០២០ | |
| | ៦.៦-ផ្សព្វផ្សាយជ្រើសរើសអ្នកចូលជា | | ២៥០ | | ០១.១២.២០១៨ | ០១.០១.២០២០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | សមាជិកសហគមន៍នេសាទ | | | | | | |
| គ៧-ផែនការបណ្តុះបណ្តាល | ៧.១-បណ្តុះបណ្តាលអំពីរបៀបសសេរកំណត់ហេតុ និងរបាយការណ៍ | គណៈកម្មការសហគមន៍នេសាទមានសមត្ថភាពក្នុងការដឹកនាំការគ្រប់គ្រង និងការកសាងឯកសារសំណុំរឿងបទល្មើសផលផល។ | ៣៥០ | អង្គការដៃគូ រដ្ឋបាលជលផល | ០១.០១.២០១៨ | ០១.០២.២០២០ | |
| | ៧.២-បណ្តុះបណ្តាលអំពីការធ្វើផែនការសកម្មភាពការងារ | | ៣៥០ | | ០១.០១.២០១៨ | ០១.០២.២០២០ | |
| | ៧.៣-បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | | ៣៥០ | | ០១.០១.២០១៨ | ០១.០២.២០២០ | |
| | ៧.៤-បណ្តុះបណ្តាលអំពីការតាមដាន និងវិភាគគុណភាពទឹក | | ៣៥០ | | ០១.០១.២០១៨ | ០១.០២.២០២០ | |
| | ៧.៥-បណ្តុះបណ្តាលអំពីនីតិវិធី និងការកសាងសំណុំរឿងបទល្មើសជលផលបឋម | | ៣៥០ | | ០១.០១.២០១៨ | ០១.០២.២០២០ | |
| គ១០-ផែនការមុខរបរចិញ្ចឹមជីវិត | ១០.១-បណ្តុះបណ្តាលវគ្គចិញ្ចឹម ជ្រូក មាន់ ទា | សមាជិកសហគមន៍មានជំនាញមានមុខរបរ និងអាចរកប្រាក់ | ៦០០ | អង្គការដៃគូ រដ្ឋបាលជលផល ថវិកាសហគមន៍ | ០១.០២.២០១៨ | ០១.០៣.២០២០ | |
| | ១០.២-បណ្តុះបណ្តាលក្រុមបណ្តុះផ្សិតចំបើង | | ៦០០ | | ០១.០២.២០១៨ | ០១.០៣.២០២០ | |
| | ១០.៣-បណ្តុះបណ្តាលក្រុមសន្សំប្រាក់ឬក្រុមជួយខ្លួនឯង | | ៦០០ | | ០១.០២.២០១៨ | ០១.០៣.២០២០ | |
| គ១១- ផែនការ រកចំណូលថវិកា | ១១.១-ភាគទានពីសមាជិកសហគមន៍នេសាទដែលទើបនឹងចូលថ្មី | សហគមន៍នេសាទនឹងមានថវិកាមកទ្រទ្រង់ការងារគ្រប់គ្រងសហគមន៍នេសាទ។ មានការចូលរួមពីអ្នកពាក់ពន្ធ័សហគមន៍នេសាទមានថវិកាអូរប្រទ្បាំភក់និងត្រូវមានការគាំទ្រឲ្យធ្វើនេសាទសិប្បកម្ម | ៧៥ | ថវិកាសហគមន៍ | ០១.០១.២០១៨ | ៣០.០៦.២០២០ | |
| | ១១.២-ភាគទានរបស់សមាជិកសហគមន៍នេសាទប្រចាំឆ្នាំ | | ៧៥ | | ០១.០១.២០១៨ | ៣០.០៦.២០២០ | |
| | ១១.៣-ធ្វើនេសាទសិប្បកម្មដើម្បីរកចំណូលគាំទ្រសហគមន៍នេសាទ | | ២០០ | | ០១.០២.២០១៨ | ០១.០៣.២០២០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ១១.៤-ធ្វើហិបភាគទានរៃអង្គៀសប្រាក់រកចំណូលគាំទ្រសហគមន៍នៃសាទបង្កើតគណៈកម្មការគ្រប់គ្រងហិបភាគទាន | ហិបសង្កសីរបស់សហគមន៍ដាក់នៅតាមវត្ត ពិធីបុណ្យ | ២០ | ថវិកាសហគមន៍ | ០១.០២.២០១៨ | ០១.០៣.២០២០ | |
| | ១១.៥-ភាគទានពីផែបណ្តែតទឹកកំសាន្ត | ធ្វើផែបណ្តែតទឹកកំសាន្តទាក់ទាញភ្ញៀវទេសចរណ៍ | ២០០០ | | ០១.០២.២០១៨ | ០១.០៣.២០២០ | |

# តារាងកម្មវិធីការងារ

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៨ | | | | | | | | | | | | ២០១៩ | | | | | | | | | | | | ២០២០ | | | | | | | | | | | |
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១.១-ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទ ដែលអនុញ្ញាត ទំហំ ពេលវេលានិងទីកន្លែងនេសាទនិងប្រភេទឧបករណ៍នេសាទហាមឃាត់ | → | | | | | | | | | | | | → | | | | | | | | | | | | → | | | | | | | | | | | |
| ១.២-ដាក់បង្ហាញស្លាកសញ្ញាពីប្រភេទឧបករណ៍នេសាទ | → | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១.៣-ចុះត្រួតពិនិត្យការធ្វើនេសាទគ្រប់ប្រភេទ | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |
| គ២-ផែនការការពារកន្លែងអភិរក្សសហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ២.១-ដាក់ក្បូនឬស្សីស្លាកសញ្ញាសំគាល់កន្លែងអភិរក្សចំនួន ៦ ស្លាក | → | → | → | → | → | → | | | | | | | | → | → | → | → | → | → | → | | | | | → | → | → | → | → | → | → | → | | | | |
| ២.២-បោះបង្គោលព្រំប្រទល់កន្លែងអភិរក្សចំនួន ៤ បង្គោល | | → | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | → |

| | |
|---|---|
| **គ៣-ផែនការពង្រឹងការគ្រប់គ្រងសហគមន៍នេសាទ** | |
| ៣.១-ពង្រឹងការងារល្បាតក្នុងសហគមន៍ | |
| ៣.២-សាងសង់ទីស្នាក់ការសហគមន៍ | |
| ៣.៣-កាណូតម៉ាស៊ីន១៣សេះ | |
| **គ៤-ផែនការប្រជុំគណៈ កម្មការនិងក្រុមល្បាត** | |
| ៤.១-ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍ | |
| ៤.២-រៀបចំមហាសន្និបាតសហគមន៍នេសាទប្រចាំឆ្នាំ | |
| ៤.៣-រៀបចំផែនការគ្រប់គ្រងឡើងវិញ | |
| ៤.៣-ប្រជុំបណ្តាញ | |
| **គ៥-ផែនការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ** | |
| ៥.១-ចុះល្បាតចំនួន ១០ ដងក្នុង១ ខែនៅរដូវប្រាំង | |
| ៥.២-ចុះល្បាតចំនួន ៥ ដងក្នុង១ ខែ នៅរដូវវស្សា | |
| **គ៦-ផែនការផ្សព្វផ្សាយ** | |

| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៦.១-ផ្សព្វផ្សាយអំពីលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងហគមន៍នេសាទ | → | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៦.២-ផ្សព្វផ្សាយអំពីកិច្ចព្រមព្រៀងប្រកាសស្តីពីការចុះបញ្ជីសហគមន៍និងផែនទីកន្លែងនេសាទសហគមន៍ | → | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៦.៣-ផ្សព្វផ្សាយអំពីផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | → | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៦.៤-ផ្សព្វផ្សាយអំពីច្បាប់ស្តីពីជលផលនិងប្រកាសពាក់ព័ន្ធ | | | | | | | | | | | | → | | | | | | | | | | | | | | | | | | | | | | | | |
| ៦.៥-ផ្សព្វផ្សាយអំពីអនុក្រឹត្យតំបន់ គ្រប់គ្រងនិងការពារសត្វផ្សោតនិង បរិស្ថាន | | | | | | | | | | | | → | | | | | | | | | | | | | | | | | | | | | | | | |
| ៦.៦-ផ្សព្វផ្សាយជ្រើសរើសអ្នកចូលជាសមាជិកសហគមន៍នេសាទ | | | | | | | | | | | | → | | | | | | | | | | | | | | | | | | | | | | | | |
| **គ៧-ផែនការបណ្តុះ បណ្តាល** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧.១-បណ្តុះបណ្តាលអំពីរបៀបសសេរកំណត់ហេតុ និងរបាយការណ៍ | → | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧.២-បណ្តុះបណ្តាលអំពីការធ្វើផែនការសកម្មភាពការងារ | → | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

| | |
|---|---|
| ៧.៣-បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | |
| ៧.៤-បណ្តុះបណ្តាលអំពីការតាមដានវិភាគគុណភាពទឹក | |
| ៧.៥-បណ្តុះបណ្តាលអំពីនីតិវិធី និងការកសាងសំណុំរឿងបទល្មើសជលផលបឋម | |
| **គ៨-ផែនការចំណូល ថវិកា** | |
| ៨.១-ភាគទានពីសមាជិកសហគមន៍នេសាទដែលទើបនឹងចូលថ្មី | |
| ៨.២-ភាគទានរបស់សមាជិកសហគមន៍នេសាទប្រចាំឆ្នាំ | |
| ៨.៣-ធ្វើនេសាទសិប្បកម្មដើម្បីរកចំណូលគាំទ្រសហគមន៍នេសាទ | |
| ៨.៤-ហិបភាគទានរៃអង្គាសរកចំណូលគាំទ្រសហគមន៍នេសាទ | |
| ៨.៥-ភាគទានពីផែបណ្តែតទឹកកំសាន្ត | |
| **គ១១-ផែនការមុខរបរចិញ្ចឹមជីវិត** | |
| ១១.១-បណ្តុះបណ្តាលវគ្គចិញ្ចឹមជ្រូក មាន់ ទា | |
| ១១.២-បណ្តុះបណ្តាលក្រុមបណ្តុះផ្សិតចំបើង | |
| ១១.៣-បណ្តុះបណ្តាលក្រុមសន្សំប្រាក់ ឬក្រុមជួយខ្លួនឯង | |

សូមគោរពជូន

លោកមេឃុំអូរគ្រៀង

" ដើម្បីពិនិត្យនិងសម្រួល"

ខ្សាច់លាវ ថ្ងៃទី២១ ខែ សីហា ឆ្នាំ២០១៧

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

**ភូមិខ្សាច់លាវ**

---

លេខ : ៧១១/ឃរគ ១៧

បានឃើញនិងគោរពជូន

លោកនាយផ្នែករដ្ឋបាលជលផលកំពី

" ដើម្បីពិនិត្យនិងសម្រួល"

អូរគ្រៀង ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០១៧

**មេឃុំអូរគ្រៀង**

កែវ បុប្ផា

---

លេខ : ០១៦ ផក.កព

បានឃើញនិងគោរពជូន

លោកនាយខណ្ឌរដ្ឋបាលជលផលក្រចេះ

" ដើម្បីពិនិត្យនិងសម្រួល"

កំពី ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ២០១៧

**នាយផ្នែករដ្ឋបាលជលផលកំពី**

---

លេខ : ១៥១ ខរ.ក្រច

បានឃើញនិងគោរពជូន

លោកប្រធាន

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្រចេះ

" ដើម្បីពិនិត្យនិងសម្រួល"

ក្រចេះ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ២០១៧

**នាយខណ្ឌរដ្ឋបាលជលផលក្រចេះ**

**សៀន គិន**

---

លេខ : ២៥៧ កសរាន.ក្រច

បានឃើញនិងគោរពជូន

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

" ដើម្បីជូនពិនិត្យនិងសម្រេចដោយអនុគ្រោះ"

ក្រចេះ ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០១៧

**ប្រធាន**

**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្រចេះ**

**គុយ ហួត**

---

លេខ : ១៣២៦ ជផ

បានឃើញ និងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ២០១៨

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

**អេង ជាសាន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ឯកសារផ្សេងៗ

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | ខ្សាច់លាវ |
| ភូមិ | ៖ | ខ្សាច់លាវ |
| ឃុំ | ៖ | អូរគ្រៀង |
| ស្រុក | ៖ | សំបូរ |
| ខេត្ត | ៖ | ក្រចេះ |

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

បកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទ

លេខៈ...០៤២៣.......ន.អ.ស

**សូមគោរពជូន**

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

**កម្មវត្ថុ** ៖ករណីសំណើសុំពិនិត្យនិងសម្រេចលើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ចំនួន១០ គឺ ៖

-សហគមន៍នេសាទកោះស័ក្តិសិទ្ធ ភូមិកោះផ្ដៅ ឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ

-សហគមន៍នេសាទអន្លង់កំពង់ក្របីត្រីប៉ាសេអ៊ី ភូមិកំពង់ក្របី ឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ

-សហគមន៍នេសាទអន្លង់វាលព្រលូងលួងចិត្ត ភូមិអំពិលទឹក ឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ

-សហគមន៍នេសាទអន្លង់កំណាប់ ភូមិកោះច្បារ ឃុំកោះខ្នែរ ស្រុកសំបូរ ខេត្តក្រចេះ

-សហគមន៍នេសាទតាកិៈខ្លាស្ទះ ភូមិកំពង់ញ្ញៅ ឃុំកោះខ្នែរ ស្រុកសំបូរ ខេត្តក្រចេះ

-សហគមន៍នេសាទពន្ធជា ភូមិពន្ធជា ឃុំអូរគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ

-សហគមន៍នេសាទកោះខ្នែរ ភូមិកោះខ្នែរ ឃុំអូរគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ

-សហគមន៍នេសាទខ្សាច់លាវ ភូមិខ្សាច់លាវ ឃុំអូរគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ

-សហគមន៍នេសាទក្បាលក្រែកមានរិទ្ធិ ភូមិបឹងចារ ឃុំបឹងចារ ស្រុកសំបូរ ខេត្តក្រចេះ

-សហគមន៍នេសាទអន្លង់គោលប្រាមានជ័យ ភូមិកំពង់ដំរី ឃុំបឹងចារ ស្រុកសំបូរ ខេត្តក្រចេះ។

**យោង** ៖-អនុក្រឹត្យលេខ២៥អនក្រ.បក ចុះថ្ងៃទី២០ខែមីនាឆ្នាំ២០០៧ស្ដីពីការគ្រប់គ្រងសហគមន៍នេសាទ

- ប្រកាសលេខ៣១៦ ប្រក.កសកចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧ ស្ដីពីគោលការណ៍ណែនាំពីសហគមន៍នេសាទ។

**ជូនភ្ជាប់**៖- លិខិតលេខ២១៥ រជ.ក្រច ចុះថ្ងៃសុក្រ ៥កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៧ របស់ខណ្ឌរដ្ឋបាលជលផលក្រចេះ ស្ដីពីសំណើសុំពិនិត្យ និងចុះហត្ថលេខាលើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ចំនួន១០សហគមន៍នេសាទ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ យោង និងជូនភ្ជាប់ខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **ឯកឧត្តមប្រតិភូ** មេត្តាជ្រាបថា សហគមន៍នេសាទទាំងអស់ដូចបានជម្រាបជូនខាងលើបានរៀបចំផែនការគ្រប់គ្រងរបស់ខ្លួន ដោយមានការឧបត្ថម្ភគាំទ្របច្ចេកទេស និងថវិកាពីរដ្ឋបាលជលផល និងអង្គការ WWF ហើយមានការសហការសម្របសម្រួលពីរដ្ឋបាលជលផលថ្នាក់កណ្ដាល ខណ្ឌរដ្ឋបាលជលផលក្រចេះ និងអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ។ ផែនការគ្រប់គ្រងនេះនឹងជាមូលដ្ឋានគ្រឹះ ដែលជាយន្តការសម្រាប់ជម្រុញដល់ដំណើរការគ្រប់គ្រងសហគមន៍នេសាទ ក្នុងការចូលរួមគ្រប់គ្រងការពារ អភិរក្ស អភិវឌ្ឍន៍ និងប្រើប្រាស់ធនធានជលផលរបស់សហគមន៍នេសាទប្រកបដោយនិរន្តរភាព លើកកំពស់កម្រិតជីវភាពរស់នៅ និងកាត់បន្ថយភាពក្រីក្រស្របតាមគោលនយោបាយកំណែ ទម្រង់ស៊ីជម្រៅវិស័យជលផលរបស់រាជរដ្ឋាភិបាលកម្ពុជា។

អាស្រ័យហេតុនេះសូម **ឯកឧត្តមប្រតិភូ** មេត្តាពិនិត្យនិងសម្រេចដោយក្ដីអនុគ្រោះ។

សូម **ឯកឧត្តមប្រតិភូ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ ។

ថ្ងៃច័ន្ទ ៦រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

រាជធានីភ្នំពេញ,ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៨

**ប្រធានស្ដីទីនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទ**

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្រចេះ**
**ខណ្ឌរដ្ឋបាលជលផលក្រចេះ**

លេខ ២១៧៤ រជ.ក្រច

ថ្ងៃ សុក្រ ៥កើត ខែ បុស្ស ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
ក្រចេះ ថ្ងៃទី ២២ ខែ ធ្នូ គ.ស ២០១៧

**សូមគោរពជូន**
**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល**

**តាមរយៈ** ៖ លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្រចេះ

**កម្មវត្ថុ** ៖ សំណើសុំពិនិត្យ និងលើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ចំនួន១០៖

**យោង** ៖ - លិខិត ២៥ អនក្រ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ

- ប្រកាសលេខ ៣១៦ ប្រក.កសក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ។

១- សហគមន៍នេសាទកោះស័ក្តសិទ្ធិ នៅភូមិកោះផ្តៅ ឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ

២-សហគមន៍នេសាទអន្លង់កំពង់ក្របីត្រីប៉ាសេអ៊ី នៅភូមិកំពង់ក្របី ឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ

៣- សហគមន៍នេសាទអន្លង់វាលព្រលូងលួងចិត្ត នៅភូមិអំពិលទឹក ឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ

៤- សហគមន៍នេសាទអន្លង់កំណប់ នៅភូមិកោះច្បារ ឃុំកោះខ្ញែរ ស្រុកសំបូរ ខេត្តក្រចេះ

៥- សហគមន៍នេសាទតាកិខ្លាស្មុះ នៅភូមិកំពង់ព្នៅ ឃុំកោះខ្ញែរ ស្រុកសំបូរ ខេត្តក្រចេះ

៦- សហគមន៍នេសាទពន្ទជា នៅភូមិពន្ទជា ឃុំអូរគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ

៧- សហគមន៍នេសាទកោះខ្ញែរ នៅភូមិកោះខ្ញែរ ឃុំអូរគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ

៨- សហគមន៍នេសាទខ្សាច់លាវ នៅភូមិខ្សាច់លាវ ឃុំអូរគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ

៩- សហគមន៍នេសាទអន្លង់ក្បាលក្រែកមានរិទ្ធិ នៅភូមិបឹងចារ ឃុំបឹងចារ ស្រុកសំបូរ ខេត្តក្រចេះ

១០- សហគមន៍នេសាទអន្លង់គោលប្រាមានជ័យ នៅភូមិកំពង់ដំរី ឃុំបឹងចារ ស្រុកសំបូរ ខេត្តក្រចេះ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមអនុញ្ញាតគោរពជម្រាបជូន **ឯកឧត្តមប្រតិភូ** មេត្តាជ្រាបថា ចាប់តាំងពីរាជរដ្ឋាភិបាលបានធ្វើកំណែទម្រង់វិស័យជលផល ខណ្ឌរដ្ឋបាលជលផលក្រចេះ បានខិតខំជំរុញដំណើរការរៀបចំសហគមន៍នេសាទនៅទូទាំងខេត្ត បានយ៉ាងទូលំទូលាយ ដោយមានការចូលរួមយ៉ាងផុសផុលពីសំណាក់ប្រជាពលរដ្ឋ ហើយមានការគាំទ្រនិងសហការយ៉ាងល្អពីអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ និងមានការ

ឧបត្ថម្ភពីអង្គការនានា។ ដំណើរការអនុវត្តរបស់សហគមន៍នេសាទទាំង ១០ ខាងលើនេះបច្ចុប្បន្នមិនទាន់មានផែនការគ្រប់គ្រងនៅឡើយ ជាពិសេសផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដែលជាមូលដ្ឋានគ្រឹះ និងជាយន្តការសម្រាប់ជំរុញដំណើរការគ្រប់គ្រងសហគមន៍នេសាទក្នុងការចូលរួមគ្រប់គ្រង ការពារ អភិរក្ស អភិវឌ្ឍ និងប្រើប្រាស់ធនធានជលផលរបស់សហគមន៍នេសាទប្រកបដោយនិរន្តរភាព លើកកំពស់ កម្រិតជីវភាពរស់នៅនិងកាត់បន្ថយភាពក្រីក្រ ស្របតាមគោលនយោបាយ កំណែទម្រង់ ស៊ីជម្រៅវិស័យជលផលនៃ រាជរដ្ឋាភិបាលកម្ពុជា។

ដូច្នេះខ្ញុំបាទ សូមអនុញ្ញាត **ឯកឧត្តមប្រតិភូ** មេត្តាពិនិត្យ និងសម្រេចលើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទាំង១០ ដើម្បីឲ្យមានការទទួលស្គាល់ជាផ្លូវការច្បាប់។

សូម **ឯកឧត្តមប្រតិភូ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

**នាយខណ្ឌរដ្ឋបាលជលផលក្រចេះ**

សៀន គិន

លេខ :……០៤៧……កសរន.ក្រច

បានឃើញ និងគោរពជូន

**ឯកឧត្តមប្រតិភូ**

" មេត្តាពិនិត្យ និងសម្រេចដោយអនុគ្រោះ"

ថ្ងៃអង្គារ ១៤កើត ខែ មាឃ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១

ក្រចេះ ថ្ងៃទី…៣០…. ខែមករា…. ឆ្នាំ២០១៨

**ប្រធាន**

**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្រចេះ**

គុយ ហួត

លេខ :…… ………..ជផ

ថ្ងៃ ខែ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី… …….. ខែ… ….. ឆ្នាំ២០១

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**